ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ:២៦៥ សជណ.៧៥

ថ្ងៃ ៧ ខែ ១០ ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ជម្រាបជូន
ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

កម្មវត្ថុ៖ ករណីអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** នៅក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ៥ឆ្នាំ ២០២០-២០២៤ នៃដំណើរឆ្ពោះទៅបរិវត្តកម្មឌីជីថល និងលើកទិសដៅការងារបន្តរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

យោង ៖- លិខិតលេខ២៩៨ បទ. ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៥ របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- លិខិតលេខ០២៩ ខន/០២៥ សជណ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៥ របស់ឧទ្ទកាល័យសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលសម្រេចឱ្យក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍(ក.ប.ទ.) និងក្រសួង ស្ថាប័នពាក់ព័ន្ធ អនុវត្តអនុសាសន៍ទាំង១១ចំណុច ដើម្បីរៀបចំជាផែនការសកម្មភាពការងារបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយប្រសិទ្ធភាព ដូចខាងក្រោម៖

១. ក.ប.ទ. ត្រូវបន្តពង្រឹងអភិបាលកិច្ចក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាឌីជីថល អភិវឌ្ឍសមត្ថភាពស្ថាប័ន និងពង្រឹងសមត្ថភាពមន្ត្រីរាជការឱ្យកាន់តែល្អប្រសើរបន្ថែមទៀត ដោយឈរលើមូលដ្ឋាននៃការកែទម្រង់ដែលបានអនុវត្តកន្លងមក ដើម្បីប្រែក្លាយទៅជាស្ថាប័នគំរូ សម្រាប់ដឹកនាំ គ្រប់គ្រងវិស័យស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួង ប្រកបដោយប្រសិទ្ធភាពខ្ពស់។

២. ក.ប.ទ. ត្រូវបន្តពន្លឿនការរៀបចំសេចក្តីព្រាងគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំពាក់ព័ន្ធក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាឌីជីថល ជាពិសេសបច្ចេកវិទ្យាឈានមុខថ្មីៗ រួមមាន បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ម៉ាស៊ីនស្វ័យសិក្សា ទិន្នន័យធំ បច្ចេកវិទ្យាក្លោដ បច្ចេកវិទ្យាប្លុកឆេន និង បច្ចេកវិទ្យាអ៊ីនធឺណិតនៃវត្ថុ។ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការគ្នាពន្លឿនការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រឱ្យបានឆាប់ ដើម្បីជាមូលដ្ឋានក្នុងបន្តការងារ។

៣. ក.ប.ទ. ត្រូវបន្តពង្រឹងគុណភាពសេវាប្រៃសណីយ៍ លើកកម្ពស់ទំនុកចិត្តលើសេវាប្រៃសណីយ៍ និងការអភិវឌ្ឍវិស័យប្រៃសណីយ៍ ដើម្បីគាំទ្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក តាមរយៈការបន្តពង្រឹងប្រតិបត្តិការរបស់សហគ្រាសប្រៃសណីយ៍កម្ពុជា ការពង្រីកបណ្តាញប្រៃសណីយ៍ឱ្យបានទូលំទូលាយ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍គន្លឹះ រួមមាន ឃ្លាំងកស្តុកការកម្មប្រៃសណីយ៍ និងកណ្តាគារគយមានដែនកំណត់ ការដឹកជញ្ជូនគោលដៅចុងក្រោយ និងការត្រៀមដាក់ឱ្យប្រើប្រាស់ថ្នាល DGPost ដើម្បីអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីប្រៃសណីយ៍រស់រវើក។ ក.ប.ទ. ក្រសួងពាណិជ្ជកម្ម និងធនាគារជាតិនៃកម្ពុជា ដែលជាតួអង្គសំខាន់ក្នុងការគាំទ្រ និងជំរុញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការដើម្បីជំរុញសកម្មភាពពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឱ្យដំណើរការបានល្អ ដោយលុបបំបាត់ការលក់ទំនិញក្លែងក្លាយ និងការបោកបញ្ឆោតតាមប្រព័ន្ធអនឡាញ។

៤. ក.ប.ទ. ត្រូវយកចិត្តទុកដាក់ពង្រឹងគុណភាពសេវា ពង្រីកវិសាលភាពនៃសេវាទូរសព្ទ និងអ៊ីនធឺណិត តាមរយៈការសាងសង់ស្ថានីយអង់តែនទូរសព្ទចល័ត ការស្ថាបនាបណ្តាញខ្សែកាបលើអាកាសនិងក្រោមដី ការបញ្ចប់គម្រោងបណ្តាញខ្សែកាបអុបទិកក្រោមបាតសមុទ្រឱ្យបានឆាប់ និងការស្ថាបនាបណ្តាញខ្សែកាបអុបទិកទៅដល់គ្រប់លំនៅឋានប្រជាពលរដ្ឋដែលមានតម្រូវការ។ ក.ប.ទ. ត្រូវរៀបចំផែនការដាក់ឱ្យដំណើរការសេវាទូរសព្ទចល័តជំនាន់ទី៥ (5G) ដើម្បីឱ្យរាជរដ្ឋាភិបាលកំណត់ពេលសមរម្យមួយក្នុងការដាក់ឱ្យដំណើរការសេវានេះ។ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចូលរួមផ្តល់កិច្ចសហការឱ្យបានពេញលេញ ក្នុងការជួយសម្រួលនិងពន្លឿននីតិវិធីផ្តល់ការអនុញ្ញាតក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល ដោយត្រូវចាត់ទុកថាសេវាទូរសព្ទនិងអ៊ីនធឺណិត គឺជាសេវាសារវន្ត ដូចសេវាអគ្គិសនីនិងទឹកស្អាតផងដែរ។ ជាមួយគ្នានេះ សូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ សូមកុំមានការព្រួយបារម្ភអំពីផលប៉ះពាល់សុខភាពបង្កមកពីស្ថានីយអង់តែនទូរសព្ទចល័ត ពីព្រោះតាមការសិក្សារបស់អង្គការសុខភាពពិភពលោក គឺពុំមានកស្តុតាងវិទ្យាសាស្ត្រណាដែលបង្ហាញថា ស្ថានីយអង់តែនទូរសព្ទចល័តអាចបង្កផលប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋទេ ហើយប្រសិនបើមានការប៉ះពាល់ដល់សុខភាពពិតមែន ប្រទេសទាំងអស់ដែលជាប្រទេសអភិវឌ្ឍ មិនប្រើប្រាស់សេវាទូរសព្ទទៀតទេ។

៥. ក.ប.ទ. ត្រូវបន្តយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង ការអភិវឌ្ឍ ការស្រាវជ្រាវ និងនវានុវត្តន៍លើវិស័យបច្ចេកវិទ្យាឌីជីថល ជាពិសេសបច្ចេកវិទ្យាឌីជីថលឈានមុខថ្មីៗ ព្រមទាំងទាញយកប្រយោជន៍ជាអតិបរមានិងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃបច្ចេកវិទ្យាទាំងនេះ។ ក.ប.ទ. ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការវិនិយោគតាមដំណាក់កាល ដើម្បីកសាងប្រព័ន្ធអេកូឡូស៊ីជាតិសម្រាប់អភិវឌ្ឍបច្ចេកវិទ្យាឈានមុខថ្មីៗ ដែលរួមមានអភិបាលកិច្ច ធនធានបច្ចេកវិទ្យាឌីជីថល ធនធានមនុស្ស បច្ចេកទេស និងការអភិវឌ្ឍ ទីផ្សារបច្ចេកវិទ្យាឌីជីថលថ្មីៗ។ ក.ប.ទ. និងគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ត្រូវរៀបចំអភិបាលកិច្ចឱ្យទាន់ពេល ដោយសារបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិតមានភាពលេចធ្លោជាងគេបង្អស់ ហើយនាំមកនូវផលវិជ្ជមាននិងអវិជ្ជមានផង។ ក.ប.ទ. ត្រូវបន្តសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ជំរុញការស្រាវជ្រាវ ការអភិវឌ្ឍ នវានុវត្តន៍ និងការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិតនេះ ដើម្បីបម្រើឱ្យការអភិវឌ្ឍក្នុងវិស័យរបស់ខ្លួន។ ក.ប.ទ. ត្រូវតាមដាន សិក្សាស្រាវជ្រាវ និងស្វែងយល់នូវគ្រប់និន្នាការវិវឌ្ឍន៍នៃបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ព្រមទាំងចូលរួមក្នុងកិច្ចប្រជុំសំខាន់ៗ ក្នុងកម្រិតតំបន់និងពិភពលោក។

៦. ក.ប.ទ. ត្រូវបន្តអភិវឌ្ឍធនធានមនុស្សឌីជីថល តាមរយៈកម្មវិធីអក្ខរកម្មឌីជីថល កម្មវិធីអប់រំឌីជីថលកម្រិតឧត្តមសិក្សា កម្មវិធីបណ្តុះបណ្តាលពង្រឹងជំនាញឌីជីថលក្នុងចំណោមមន្ត្រីរាជការ និងកម្មវិធីភាពជាអ្នកដឹកនាំឌីជីថល។ ក.ប.ទ. ត្រូវរៀបចំផែនការបង្កើនការយល់ដឹងអក្ខរកម្មឌីជីថលឱ្យស្របតាម "ក្របខ័ណ្ឌសមត្ថភាពអក្ខរកម្មឌីជីថល ប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន"។ ចំពោះកម្មវិធីអប់រំឌីជីថលកម្រិតឧត្តមសិក្សា រាជរដ្ឋាភិបាលគាំទ្រនិងលើកទឹកចិត្តឱ្យ ក.ប.ទ. បន្តផ្តល់អាហារូបករណ៍ និងជំនួយហិរញ្ញវត្ថុដល់សិស្សឆ្នើមឱ្យបានកាន់តែច្រើន និងបន្តអនុវត្តគម្រោងប្រកួតប្រជែងនៅកម្រិតគ្រឹះស្ថានអប់រំ ដើម្បីបញ្ជាបនិងផ្សព្វផ្សាយការយល់ដឹងអំពីសារៈសំខាន់នៃបច្ចេកវិទ្យាឌីជីថលជាសាធារណៈ និងគាំទ្រចំពោះ ក.ប.ទ. ដែលបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការជំរុញការធ្វើបរិវត្តកម្មឌីជីថលនិងការផ្តល់មធ្យោបាយបច្ចេកវិទ្យាឌីជីថលដល់គ្រឹះស្ថានឧត្តមសិក្សា ជាពិសេស ក្នុងការផ្សារភ្ជាប់ការអប់រំជំនាញឌីជីថលទៅនឹងសួនឌីជីថល (Digital Park) ដែលជាគំនិតផ្តួចផ្តើមថ្មីមួយ ដើម្បីលើកកម្ពស់គុណភាពអប់រំឱ្យបានកាន់តែល្អប្រសើរ និងផ្តល់លទ្ធភាពងាយស្រួល ដល់សិស្សនិស្សិត អាចទទួលបានការងារនៅកន្លែងផ្ទាល់ ឬការងារពីចម្ងាយ ដោយសហការជាមួយក្រុមហ៊ុនធំៗ នៅតំបន់ Silicon Valley នៃសហរដ្ឋអាម៉េរិក និងមជ្ឈមណ្ឌលធុរកិច្ចថ្មីឌីជីថលផ្សេងៗទៀត។

៧. ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវតែរៀបចំធនធានមនុស្សជំនាញឌីជីថល សម្រាប់គាំទ្រដល់ដំណើរការនៃការធ្វើបរិវត្តកម្មឌីជីថលផ្ទៃក្នុង និងការផ្តល់សេវាសាធារណៈឌីជីថលដល់វិស័យឯកជន និងប្រជាពលរដ្ឋ ដើម្បីជំរុញការកសាងរដ្ឋាភិបាលឌីជីថល។ រាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យ ក.ប.ទ. បន្តជួយបណ្តុះបណ្តាលមន្ត្រីរាជការឱ្យចេះប្រើប្រាស់ឧបករណ៍ឌីជីថល និងកម្មវិធីសុសវែរផ្សេងៗសម្រាប់កិច្ចការការិយាល័យ និងជំរុញបញ្ចប់ការកសាងផែនការសកម្មភាពបរិវត្តកម្មឌីជីថលនៅតាមក្រសួង ស្ថាប័នដែលមិនទាន់បានរៀបចំ។ ក.ប.ទ. ត្រូវបន្តសហការជាមួយក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍នៃការរៀបចំអង្គភាពបរិវត្តកម្មឌីជីថលនៅតាមក្រសួង ស្ថាប័ន ប៉ុន្តែចំពោះការអនុវត្តការងារបរិវត្តកម្មឌីជីថលដែលជាមុខងារគាំទ្រ ត្រូវរង់ចាំរហូតដល់មានការសម្រេចអនុញ្ញាតសិន។ គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភាត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំសេវាសាធារណៈឌីជីថលនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ឱ្យទូលំទូលាយនិងមានប្រសិទ្ធភាពខ្ពស់។

៨. ក.ប.ទ. ត្រូវយកចិត្តទុកដាក់គិតគូរអំពីអភិបាលកិច្ចនិងការគ្រប់គ្រងទិន្នន័យ ការរៀបចំនិម្មាបនកម្មរដ្ឋាភិបាលឌីជីថល ការធ្វើអន្តរប្រតិបត្តិការ ការធ្វើកូដនីយកម្មទិន្នន័យ និងការរក្សាទុកទិន្នន័យនៅក្រសួង ស្ថាប័នសាមី ស្របតាមគោលការណ៍សុវត្ថិភាពទិន្នន័យ និងសន្តិសុខសាយប័រ។ ក.ប.ទ. ត្រូវពន្លឿនការសាងសង់មជ្ឈមណ្ឌលទិន្នន័យជាតិឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ រាល់ការអភិវឌ្ឍថ្មីលនិងកម្មវិធីឌីជីថលរបស់គ្រប់ក្រសួង ស្ថាប័ន ត្រូវឆ្លងការពិនិត្យ និងវាយតម្លៃផ្នែកបច្ចេកទេសដោយគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល។

៩. គាំទ្រដល់ការដាក់ឱ្យប្រើប្រាស់សាកល្បងនូវថ្មីល DG SuperApp នៅខែមីនា ឆ្នាំ២០២៥ ខាងមុខនេះ។

១០. ក.ប.ទ. ត្រូវផ្តល់កិច្ចសហការ និងជំនួយបច្ចេកទេសផ្នែកសន្តិសុខសាយប័រដល់ក្រសួង ស្ថាប័ន ដើម្បីការពារថ្មីលនិងកម្មវិធីឌីជីថល តាមរយៈការពង្រឹងយន្តការធ្វើឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រ (CamCERT)

ការដាក់ឱ្យអនុវត្តបទប្បញ្ញត្តិផ្ទៃក្នុងនៃការគ្រប់គ្រងសន្តិសុខសាយប័រ និងការដាក់ឱ្យអនុវត្តនិម្មាបនកម្មសន្តិសុខសាយប័រនៅតាមក្រសួង ស្ថាប័ន ដើម្បីអាចតភ្ជាប់មកមជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខរបស់ ក.ប.ទ.។ ក្រសួង ស្ថាប័ន ដែលមិនទាន់មានបទប្បញ្ញត្តិផ្ទៃក្នុងនិងនីតិវិធីនេះ អាចពិចារណាយកទៅប្រើប្រាស់តាមតម្រូវការបាន។ ក.ប.ទ. ត្រូវបន្តចូលរួមជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាឱ្យកាន់តែមានប្រសិទ្ធភាព ក៏ដូចជាជំរុញយុទ្ធនាការផ្សព្វផ្សាយ ការយល់ដឹងអំពីសុវត្ថិភាពអនឡាញជាពិសេស ការការពារកុមារតាមប្រព័ន្ធអនឡាញ និងការផ្សព្វផ្សាយតាមក្រុមហ៊ុនបច្ចេកវិទ្យានិងគ្រឹះស្ថានអប់រំ ។ល។

១១. លើកទឹកចិត្តឱ្យសហប្រធានក្រុមការងារផ្នែកសេដ្ឋកិច្ច សង្គមឌីជីថល និងទូរគមនាគមន៍ (ក្រុមការងារ "ណ") នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន បន្តពិភាក្សាលើសំណូមពរនិងបញ្ហាប្រឈមនានា ព្រមទាំងចូលរួមជំរុញនិងទាក់ទាញធុរកិច្ច និងការវិនិយោគបន្ថែមក្នុងវិស័យឌីជីថល ដើម្បីទទួលបានលទ្ធផលជាផ្លែផ្កាច្រើនបន្ថែមទៀត សម្រាប់សង្គមនិងសេដ្ឋកិច្ចជាតិ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

ជ. រដ្ឋមន្ត្រីទទួលបន្ទុកនីតិវិធីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ហ៊ុយ ទណ្ឌៈ

ចម្លងជូន៖
- គ្រប់ក្រសួង ស្ថាប័ន
- ឧទ្ធកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ឧទ្ធកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ